ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកញ្ញា និងទិសដៅការងារខែតុលា ឆ្នាំ២០២៥

នៅក្នុងខែកញ្ញា ឆ្នាំ២០២៥ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានផ្តល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

## I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥

### ១-មុខងារនីតិកម្ម

- **បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងារនីតិកម្ម រួមមាន៖**
  - ❖ កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន៣លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុច បូរិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងបន្ថែមទៅលើសន្ធិសញ្ញាស្តីពីតំបន់អាស៊ី-អាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែរ។
  - ❖ បើកសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៥ ចំនួន២លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុច បូរិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា និង
  - ❖ ប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ ចំនួន១ច្បាប់។

### ២-មុខងារតាមដានការអនុវត្តច្បាប់

- **បានរៀបចំចាត់ចែង និងផ្តល់សេវាជូនគណៈកម្មការនានារបស់ព្រឹទ្ធសភា អញ្ជើញចុះបំពេញបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា រួមមាន៖**
  - ❖ គណៈកម្មការទី២ព្រឹទ្ធសភា៖
    - ▪ បានអញ្ជើញជួបពិភាក្សាការងារជាមួយ **លោកជំទាវបណ្ឌិត សោម គឹមសួគ៌** អគ្គសវនករនៃអាជ្ញាធរសវនកម្មជាតិ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងាររបស់អាជ្ញាធរសវនកម្មជាតិ

បេសកកម្ម ចក្ខុវិស័យ ឱកាស និងបញ្ហាប្រឈមនានា ជាពិសេសបង្កើនកិច្ចសហការការងារ នៅទីស្តីការអាជ្ញាធរសេវនកម្មជាតិ។

- បានអញ្ជើញជួបពិភាក្សាការងារជាមួយ **ឯកឧត្តមបណ្ឌិត គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងាររបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ចក្ខុវិស័យ ផែនការយុទ្ធសាស្ត្រ ការប្រមូលពន្ធគយ និងបញ្ហាប្រឈមនានា ជាពិសេសបង្កើនកិច្ចសហការការងារ នៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និង
- បានអញ្ជើញជួបពិភាក្សាការងារជាមួយ **ឯកឧត្តម គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងាររបស់អគ្គនាយកដ្ឋានពន្ធដារ ចក្ខុវិស័យ ផែនការយុទ្ធសាស្ត្រ ការប្រមូលពន្ធ និងបញ្ហាប្រឈម ជាពិសេសបង្កើនកិច្ចការងារ នៅអគ្គនាយកដ្ឋានពន្ធដារ។

❖ គណៈកម្មការទី៣ព្រឹទ្ធសភា បានជួបពិភាក្សាការងារជាមួយ **ឯកឧត្តម ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីឈ្វេងយល់ពីវឌ្ឍនភាពការងារ បញ្ហាប្រឈមនានាកន្លងមក និងចក្ខុវិស័យរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

❖ គណៈកម្មការទី៤ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយ ឯកឧត្តមប្រធានក្រុមប្រឹក្សាខេត្ត ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត កងកម្លាំងប្រដាប់អាវុធទាំង៣ប្រភេទ មន្ទីរជំនាញជុំវិញខេត្ត និងសមាជិក សមាជិកាក្រុមប្រឹក្សាឃុំ-សង្កាត់ទូទាំងខេត្តរតនគិរី នៅសាលមហោស្រពរតនៈ ក្រុងបានលុង ខេត្តរតនគិរី។

❖ គណៈកម្មការទី៥ព្រឹទ្ធសភា បានជួបពិភាក្សាការងារជាមួយៈ

- **ឯកឧត្តម ញ៉ែម សំអឿន** អភិបាលនៃគណៈអភិបាលខេត្តរតនគិរី និងដើម្បីឈ្វេងយល់ពី ១/ការងារអន្តោប្រវេសន៍ និងវឌ្ឍនភាពនៃការអនុវត្តច្បាប់អន្តោប្រវេសន៍ ២/ការងារព័ត៌មាន វឌ្ឍនភាពនៃការអនុវត្តច្បាប់សារព័ត៌មាន ការគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដូចជាៈ វិទ្យុ ទូរទស្សន៍ ព័ត៌មានអនឡាញ និងព័ត៌មានទាន់ហេតុការណ៍ និងកិច្ចសហប្រតិបត្តិការការអភិវឌ្ឍលើវិស័យនានារបស់ខេត្តរតនគិរី និងពង្រឹងទំនាក់ទំនងកាន់តែជិតស្និទ្ធរវាងព្រឹទ្ធសភាជាមួយអាជ្ញាធរខេត្តគ្រប់លំដាប់ថ្នាក់។
- អាជ្ញាធរស្រុកអូរយ៉ាដាវ និងអាជ្ញាធរប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិអូរយ៉ាដាវ នៅទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិអូរយ៉ាដាវ ខេត្តរតនគិរី។
- **ឯកឧត្តមឧត្តមសេនីយ៍ឯក សុខ វាសនា** អគ្គនាយកអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ ធ្វើសេចក្តីរាយការណ៍អំពីការងារសំខាន់ៗរបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ នៅសាលពិសេស៣ វិមានព្រឹទ្ធសភា រួមមានៈ ១/របាយការណ៍ប្រចាំឆ្នាំ២០២៤ និងរបាយការណ៍ឆមាសទី១ឆ្នាំ២០២៥ ២/វឌ្ឍនភាពនៃការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីអន្តោប្រវេសន៍ថ្មី ៣/ការគ្រប់គ្រងជនបរទេសអន្តោប្រវេសន៍ ជនបរទេសអន្តោប្រវេសន៍ជាអ្នកវិនិយោគ ៤/សំណួរ-ចម្លើយ និងសំណូមពរ និង៥/បញ្ហាផ្សេងៗ។

❖ គណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយនឹងសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីសិក្សាឈ្វេងយល់ប្រមូលព័ត៌មានពាក់ព័ន្ធទៅនឹងការអនុវត្តច្បាប់ ការផ្តល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ដែលសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ជួបប្រទះនាពេលអនុវត្តការងារ នៅសាលប្រជុំសាលាឧទ្ធរណ៍ភ្នំពេញ និង

❖ គណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចុះជួបស្តាប់ដើម្បីទទួលព័ត៌មានអំពីសភាពការណ៍ថ្មីៗ និងពិភាក្សាការងារជាមួយរដ្ឋបាលខេត្តស្វាយរៀង និងខេត្តព្រៃវែង នៅសាលាខេត្តស្វាយរៀង និងខេត្តព្រៃវែង។

## ៣-មុខងារតំណាង

- **បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា រួមមាន៖**

❖ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា៖**

- **សកម្មភាពចូលរួមពិធីផ្សេងៗ៖**
  - បានអញ្ជើញជាអធិបតីក្នុងមហាសន្និបាតវិសាមញ្ញតំណាងសមាគមអតីតយុទ្ធជនកម្ពុជាទូទាំងប្រទេស នៅទីស្តីការក្រសួងមហាផ្ទៃ រាជធានីភ្នំពេញ និង
  - បានអញ្ជើញចូលរួមពិធីបុណ្យភ្ជុំបិណ្ឌនៅវត្តមុនីសុវណ្ណ (ហៅវត្តចំពុះក្អែក) នៅខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

❖ **ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី១ព្រឹទ្ធសភា៖**

- **បេសកកម្មក្នុងប្រទេស៖**
  - បានអញ្ជើញជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី** ចុះសួរសុខទុក្ខក្រុមគ្រួសាររបស់វីរយុទ្ធជនដែលកំពុងឈរជើង នៅសមរភូមិជួរមុខ ចំនួន៣០០គ្រួសារ មកពីឃុំមរកត ឃុំយាង ឃុំទឹកក្រហម និងឃុំស្រអែមនៃស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ព្រមទាំងតំណាងវីរយុទ្ធជនការពារប្រាសាទតាមាន់ និងប្រាសាទតាក្របី ខេត្តឧត្តរមានជ័យ និង
  - បានអញ្ជើញចុះជួបសំណេះសំណាល និងផ្សព្វផ្សាយអំពីសភាពការណ៍កម្ពុជាជូនដល់មន្ត្រីរាជការ ប្រជាពលរដ្ឋ ក្នុងស្រុកព្រៃឈរ ស្រុកជើងព្រៃ និងស្រុកបាធាយ ខេត្តកំពង់ចាម ចំនួន៩១៣នាក់។
- **សកម្មភាពចូលរួមពិធីផ្សេងៗ៖** បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ចូលរួមពិធីគោរពរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា រំលឹកខួប៣២ឆ្នាំ "ទិវាប្រកាសរដ្ឋធម្មនុញ្ញ" នៅនីតិបូជនីយដ្ឋាន នៅសួនច្បារខាងលិចវិមានឯករាជ្យ។

❖ **ឯកឧត្តមបណ្ឌិត ឆន់ ខញ្ញា អនុប្រធានទី២ព្រឹទ្ធសភា៖**

- **សកម្មភាពដឹកនាំកិច្ចប្រជុំ៖** បានអញ្ជើញដឹកនាំកិច្ចប្រជុំប្រចាំខែ ជាមួយប្រធានគណៈកម្មការទាំង១០ព្រឹទ្ធសភា ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ ប្រធានក្រុមសមាជិកាព្រឹទ្ធសភា និងប្រធានគណៈកម្មការក្រុមសីលធម៌សភារបស់

ព្រឹទ្ធសភា ដោយពិភាក្សាលើរបៀបវារៈ ស្តីពី គំនិតផ្តួចផ្តើមរបស់ព្រឹទ្ធសភាចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមតាមព្រំដែន និងការងារផ្សេងៗ នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។

- **សកម្មភាពចុះមូលដ្ឋាន៖**
  - បានចាត់តំណាងប្រគល់សម្ភារមួយចំនួនជូនដល់កងពលតូចអន្តរាគមន៍លេខ៩ ប្រចាំទិសមុំបី ខេត្តព្រះវិហារ។
  - បានចាត់តំណាងប្រគល់សម្ភារមួយចំនួនជូនដល់កងពលតូចអន្តរាគមន៍លេខ១ ឈរជើងនៅច្រកតាថាវ និង
  - បានអញ្ជើញទស្សនកិច្ចសិក្សា នៅសិប្បកម្មផលិត និងកែច្នៃប្រហុក ផលិតផលរបស់កម្ពុជា ( CONFIREL Prahok Manufacturing ) ដោយមានការចូលរួមពីទីប្រឹក្សា ថ្នាក់ដឹកនាំខុទ្ទកាល័យ និងលោកគ្រូ អ្នកគ្រូនៃវិទ្យាស្ថានជាតិកសិកម្មព្រែកលៀប នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។
- **សកម្មភាពចូលរួមពិធីផ្សេងៗ៖** បានអញ្ជើញចូលរួមពិធីបុណ្យកាន់បិណ្ឌ ដើម្បីឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខន្ធបុព្វការីជន ព្រមទាំងញាតិកាទាំងប្រាំពីរសន្តាន ចំនួន៧វត្ត នៅរាជធានីភ្នំពេញ និងខេត្តកំពង់ចាម។

❖ **ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា** បានអញ្ជើញចូលរួមពិធីកាន់បិណ្ឌ និងបុណ្យភ្ជុំបិណ្ឌតាមប្រពៃណី និងគន្លងព្រះពុទ្ធសាសនា នៅតាមវត្តអារាមនានា នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។

❖ **សមាជិក សមាជិកាព្រឹទ្ធសភា៖**

- បានអញ្ជើញចូលរួមជាមួយគណៈប្រតិភូព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយ **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា តំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី** អញ្ជើញចុះសួរសុខទុក្ខក្រុមគ្រួសាររបស់វីរយុទ្ធជនដែលកំពុងឈរជើង នៅសមរភូមិជួរមុខ ចំនួន៣០០គ្រួសារ មកពីឃុំមរកត ឃុំយាង ឃុំទឹកក្រហម និងឃុំស្រអែមនៃស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ព្រមទាំងតំណាងវីរយុទ្ធជនការពារប្រាសាទតាមាន់ និងប្រាសាទតាក្របី ខេត្តឧត្តរមានជ័យ។
- បានអញ្ជើញចូលរួមប្រជុំក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា ដើម្បីត្រៀមជួបសម្តែងការគួរសមជាមួយ **ឯកឧត្តម TSUTSUMI** Naohiro ឯកអគ្គរដ្ឋទូតទទួលបន្ទុកកិច្ចការសិទ្ធិមនុស្ស សន្តិភាព និងស្ថិរភាពអន្តរជាតិនៃក្រសួងការបរទេសជប៉ុន ចូលជួបពិភាក្សាការងារអំពីវឌ្ឍនភាពស្ថានភាពសិទ្ធិមនុស្សនៅព្រះរាជាណាចក្រកម្ពុជា នៅបន្ទប់ប្រជុំខុទ្ទកាល័យឯកឧត្តមបណ្ឌិតអនុប្រធានទី២ព្រឹទ្ធសភា។
- បានអញ្ជើញចូលរួមកិច្ចប្រជុំក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភាស្តីពី គំនិតផ្តួចផ្តើមរបស់ព្រឹទ្ធសភាចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមតាមព្រំដែន និងការងារផ្សេងៗ នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។

- បានអញ្ជើញចូលរួមពិធីសំណេះសំណាល សួរសុខទុក្ខ និងចែកអំណោយមនុស្សធម៌ ដល់សមាជិកមូលនិធិត្រីចក្រយានកម្ពុជា ចំនួន៣៨៦នាក់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ របស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា នៅទីស្នាក់ការកណ្តាលកាកបាទក្រហមកម្ពុជា រាជធានីភ្នំពេញ។
- បានអញ្ជើញជាអធិបតីក្នុងពិធីប្រកាសជ័យលាភីឃុំ-សង្កាត់ ដែលបានចូលរួមចលនាប្រឡងប្រណាំង "ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព" ក្នុងក្របខ័ណ្ឌលក្ខណៈសម្បត្តិទី៦ ឆ្នាំ២០២៥ និងការផ្សព្វផ្សាយគោលនយោបាយ "ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព" នៅទីស្តីការក្រសួងបរិស្ថាន។
- បានអញ្ជើញចូលរួមក្នុងពិធីប្រកាសកាន់មុខតំណែងអភិបាលនៃគណៈអភិបាលខេត្តកោះកុង នៅសាលប្រជុំសាលាខេត្តកោះកុង។
- បានអញ្ជើញជួបពិភាក្សាការងារជាមួយ **ឯកឧត្តមបណ្ឌិតសភាចារ្យ ផាន់ ផល្លា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅសាលពិសេសជាន់ក្រោម វិមានព្រឹទ្ធសភា។
- បានអញ្ជើញប្រគល់ឱសថ ឧបករណ៍វេជ្ជសាស្ត្រ និងសម្ភារប្រើប្រាស់ប្រចាំថ្ងៃ ជូនរដ្ឋបាលខេត្តស្ទឹងត្រែង ខេត្តព្រះវិហារ និងរដ្ឋបាលស្រុកស្រីសន្ធរ ខេត្តកំពង់ចាម រដ្ឋបាលស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
- បានអញ្ជើញចូលរួមកិច្ចប្រជុំផ្សព្វផ្សាយការងារចលនាសហជីព និងការងាររណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជារាជធានី នៅខណ្ឌសែនសុខ រាជធានីភ្នំពេញ។
- បានអញ្ជើញចុះសួរសុខទុក្ខ ចែកអំណោយ និងថវិកាមួយចំនួនជូនប្រជាពលរដ្ឋភៀសសឹក ចំនួន៧៤០គ្រួសារ ដែលកំពុងស្នាក់នៅបណ្តោះអាសន្នក្នុងមណ្ឌលសុវត្ថិភាពវត្តឧត្តមគិរីទួលអណ្តែត (វត្តថ្មល់បែក) នៅស្រុកគូលែន ខេត្តព្រះវិហារ។
- បានអញ្ជើញធ្វើពិធីសំណេះសំណាល សួរសុខទុក្ខ និងចែកចង្ក្រានសន្សំសំចៃថាមពលសារុង និងថវិកាមួយចំនួនជូនប្រជាពលរដ្ឋ ចំនួន៧០៦គ្រួសារ នៅស្រុកស្ទោង ខេត្តកំពង់ធំ។
- ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាលសាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល ប្រធានមណ្ឌលសុខភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី៥ នៅមូលដ្ឋាន ឈ្វេងយល់អំពីវឌ្ឍនភាពការងារសន្តិសុខ សណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា **ចំនួន១២៣លើក** ព្រមទាំងបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធសមិទ្ធផលនានា និងពិធីផ្លូវការផ្សេងៗ **ចំនួន១០៧លើក**។

- **សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖**
  - ❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា៖
    - បានអញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ព្រមទាំងក្រុមគ្រួសារ អញ្ជើញចូលរួមពិធីបុណ្យភ្ជុំបិណ្ឌនៅវត្តមុនីសុវណ្ណ (ហៅវត្តចំពុះក្អែក) នៅខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ និង
    - បានអញ្ជើញចូលរួមអម **ឯកឧត្តម អ៊ុច បូររិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ចូលរួមពិធីគោរពរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា រំលឹកខួប៣២ឆ្នាំ "ទិវាប្រកាសរដ្ឋធម្មនុញ្ញ" នៅនីតិបូជនីយដ្ឋាន នៅសួនច្បារខាងលិចវិមានឯករាជ្យ។
  - ❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និង**ឯកឧត្តម អោក ប៉ូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីបុណ្យកាន់បិណ្ឌវេនទី៥ នៅវត្តវារិន្ទ វត្តមង្គលសត្ថាវ៉ន និងវត្តសូរិយាពោធិមាស នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។
  - ❖ **ឯកឧត្តម ខេង សិទ្ធិគុណ ឯកឧត្តម អោក ប៉ូរ៉ា** និង**ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានដឹកនាំគណៈប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញគោរពវិញ្ញាណក្ខន្ធសព **ឧបាសិកាពុទ្ធសាសនូបត្ថម្ភក៏ មាយ ផល** ម្តាយក្មេករបស់ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា នៅសង្កាត់ក្បាលកោះ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។
  - ❖ **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងចូលរួមពិធីផ្សេងៗ ចំនួន៥លើក។
  - ❖ **ឯកឧត្តម អោក ប៉ូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងចូលរួមពិធីផ្សេងៗ ចំនួន៥លើក និង
  - ❖ **ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងចូលរួមពិធីផ្សេងៗ ចំនួន៣លើក។
- បានរៀបចំអំណោយជូនគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ចំនួន៣០កញ្ចប់ និង
- បានទទួលពាក្យបណ្តឹង ចំនួន៩បណ្តឹង បញ្ជូនពាក្យបណ្តឹងចេញទៅក្រសួង ស្ថាប័ន និងខេត្តពាក់ព័ន្ធ ចំនួន៥បណ្តឹង កំពុងពិនិត្យសិក្សា ចំនួន៩បណ្តឹង បានទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្តឹង ចំនួន៥បណ្តឹង ធ្វើកំណត់បង្ហាញគោរពរាយការណ៍ជូន សម្តេចតេជោ ប្រធានព្រឹទ្ធសភា អំពីការឆ្លើយតបលទ្ធផលដោះស្រាយបណ្តឹងរបស់ក្រសួង ស្ថាប័ន និងខេត្តពាក់ព័ន្ធ ចំនួន១បណ្តឹង ផ្តល់ព័ត៌មានទៅម្ចាស់បណ្តឹង ចំនួន៥បណ្តឹង ទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ចំនួន២៦បណ្តឹង។

## ៤-មុខងារសហប្រតិបត្តិការអន្តរជាតិ

- បានរៀបចំចាត់ចែង និងផ្តល់សេវាជូនប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា និងថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា រួមមាន៖

❖ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្តីទី៖

- **បដិសណ្ឋារកិច្ចភ្ញៀវអន្តរជាតិ៖**
  - បានទទួលសារតាំងពី ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព ទើបតែងតាំងថ្មី ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅវិមានព្រឹទ្ធសភា ចំនួន២លើក រួមមាន៖
    
    ១/ **ឯកឧត្តម** Daouda Bitie ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព ទើបតែងតាំងថ្មីនៃសាធារណរដ្ឋប្រជាមានិតបួគីណាហ្វាសូ និង
    
    ២/ **លោកជំទាវ** Vivian Loss Sanmartin ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព ទើបតែងតាំងថ្មីនៃសាធារណរដ្ឋសហព័ន្ធប្រេស៊ីល។
  - បានអញ្ជើញទទួលបដិសណ្ឋារកិច្ចស្វាគមន៍ការបំពេញទស្សនកិច្ចផ្លូវរដ្ឋរបស់ **ឯកឧត្តម** Ferdinand Romualdez Marcos Jr. ប្រធានាធិបតីនៃសាធារណរដ្ឋហ្វីលីពីន និង **លោកជំទាវ** Louise Araneta-Marcos រយៈពេល២ថ្ងៃ នៅព្រះរាជាណាចក្រកម្ពុជា ដោយក្នុងឱកាសទស្សនកិច្ចនោះ **សម្តេចតេជោប្រធានព្រឹទ្ធសភា** បានជួបពិភាក្សាការងារជាមួយ ឯកឧត្តមប្រធានាធិបតីនៃសាធារណរដ្ឋហ្វីលីពីន ក្នុងកិច្ចប្រជុំកំពូល ព្រមទាំងបានអញ្ជើញជាអធិបតីក្នុងពិធីលៀងសាយភោជន៍ផ្លូវរដ្ឋជូន ឯកឧត្តមប្រធានាធិបតីនៃសាធារណរដ្ឋហ្វីលីពីន និងលោកជំទាវ នៅវិមានសន្តិភាព។
  - បានទទួលជួបពិភាក្សាការងារ និងអនុញ្ញាតឱ្យភ្ញៀវអន្តរជាតិ ចូលជួបសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា ចំនួន៥លើក រួមមាន៖
    
    ១/ **លោកជំទាវ** Bridgette L. Walker ភារធារីស្តីទីស្ថានទូតសហរដ្ឋអាមេរិក។
    
    ២/ **ឯកឧត្តម** Olivier Richard ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋបារាំង។
    
    ៣/ **ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត** Sir Konstantin ( Kostya ) S. Novoselov FRS អ្នកទទួលពានរង្វាន់ណូបែលរូបវិទ្យា។
    
    ៤/ **ឯកឧត្តម** Sardar Umar Alam តំណាងអង្គការយូណេស្កូ ប្រចាំព្រះរាជាណាចក្រកម្ពុជា និង
    
    ៥/ **ឯកឧត្តមឧត្តមសេនីយ៍ទោ** Dato Paduka Seri Haji Muhammad Haszaimi bin Bol Hassan មេបញ្ជាការកងយោធពលភូមិន្ទនៃប្រទេសប្រ៊ុយណេ។
- **បេសកកម្មក្រៅប្រទេស៖** បានអញ្ជើញដឹកនាំគណៈប្រតិភូកម្ពុជា ទៅបំពេញទស្សនកិច្ច និងចូលរួមពិធីរំលឹកខួបអនុស្សាវរីយ៍លើកទី៨០នៃបដិវត្តន៍ខែសីហា និងទិវាបុណ្យឯករាជ្យជាតិវៀតណាម (២ កញ្ញា ១៩៤៥ - ២ កញ្ញា ២០២៥) នៅទីក្រុងហាណូយ សាធារណរដ្ឋសង្គមនិយមវៀតណាម ដោយក្នុងឱកាសនោះ **សម្តេចតេជោ** បានជួបពិភាក្សាការងារ

ជាមួយឥស្សរជនជាន់ខ្ពស់វៀតណាម ចំនួន៣លើក និងចូលរួមពិធីលៀងសាយភោជន៍ ចំនួន១លើក រួមមាន៖

១/ **ឯកឧត្តម** Tran Thanh Man ប្រធានរដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅវិមានរដ្ឋសភា។

២/ **ឯកឧត្តម** To Lam អគ្គលេខាធិការគណបក្សកុម្មុយនីស្តវៀតណាម នៅទីស្នាក់ការមជ្ឈិមបក្សវៀតណាម។

៣/ **ឯកឧត្តម** Pham Minh Chinh នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅវិមាននាយករដ្ឋមន្ត្រី និង

៤/ ចូលរួមពិធីលៀងសាយភោជន៍ រៀបចំដោយ **ឯកឧត្តម** To Lam ជូនចំពោះថ្នាក់ដឹកនាំ និងគណៈប្រតិភូគ្រប់បណ្តាប្រទេស ដែលអញ្ជើញចូលរួមពិធីរំលឹកខួបអនុស្សាវរីយ៍នេះ។

- **សកម្មភាពចូលរួមពិធីផ្សេងៗ៖** បានអញ្ជើញជាអធិបតីក្នុងពិធីខួបអនុស្សាវរីយ៍លើកទី៧៦ នៃការបង្កើតសាធារណរដ្ឋប្រជាមានិតចិន ១៩៤៩-២០២៥ នៅសណ្ឋាគារសុខាភ្នំពេញ។

❖ **ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី១ព្រឹទ្ធសភា៖**

- **បដិសណ្ឋារកិច្ចភ្ញៀវអន្តរជាតិ៖**
  - បានអនុញ្ញាតឱ្យគណៈប្រតិភូអូស្ត្រាលី ដឹកនាំដោយ **លោកជំទាវ** Fiona Phillips សមាជិកសភា និងជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងដឹកជញ្ជូនក្នុងតំបន់ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅវិមានព្រឹទ្ធសភា និង
  - បានអញ្ជើញចូលរួមពិធីពិសាអាហារថ្ងៃត្រង់ជាមួយឯកអគ្គរាជ/រដ្ឋទូតអាស៊ាន រៀបចំដោយ **ឯកឧត្តម** U Kyaw Soe Min ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារហ៊ីម៉ាវ៉ារី រាជធានីភ្នំពេញ។
- **បេសកកម្មក្រៅប្រទេស៖** បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ចូលរួម "សន្និសីទសាមគ្គីភាពសង្គមស៊ីវិលអន្តរជាតិលើកទី២ ស្តីពី គំនិតផ្តួចផ្តើមអភិវឌ្ឍន៍សកល" នៅទីក្រុងហូហាត តំបន់ស្វយ័តម៉ុងហ្គោលី សាធារណរដ្ឋប្រជាមានិតចិន។

❖ **ឯកឧត្តមបណ្ឌិត ឆន់ ខន្ធរ្យនា អនុប្រធានទី២ព្រឹទ្ធសភា៖**

- **សកម្មភាពចូលរួមកិច្ចប្រជុំ៖** បានអញ្ជើញប្រជុំការងារជាមួយ **ឯកឧត្តម** IGOR Driesmans ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុប ប្រចាំព្រះរាជាណាចក្រកម្ពុជា អំពីកិច្ចសហប្រតិបត្តិការរវាងព្រឹទ្ធសភាកម្ពុជា និងសហភាពអឺរ៉ុប នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
- **បដិសណ្ឋារកិច្ចភ្ញៀវអន្តរជាតិ៖**
  - បានអញ្ជើញចូលរួមពិធីលៀងសាយភោជន៍ផ្លូវរដ្ឋ រៀបចំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ជាកិត្តិយសជូនចំពោះ ឯកឧត្តមប្រធានាធិបតីនៃសាធារណរដ្ឋហ្វីលីពីន និងលោកជំទាវ នៅវិមានសន្តិភាព និង

- បានអនុញ្ញាតឱ្យថ្នាក់ដឹកនាំសាលាអន្តរជាតិផារ៉ាហ្គូន និងសាកលវិទ្យាល័យអន្តរជាតិផារ៉ាហ្គូន ដឹកនាំដោយ **លោក Artur Tulepbekov** តំណាងនាយកប្រតិបត្តិ ចូលជួបសម្តែងការគួរសម នៅសាលប្រជុំឧទ្ទកាល័យអនុប្រធានទី២ វិមានព្រឹទ្ធសភា។

❖ **លោកជំទាវបណ្ឌិត អ៊ុក ម៉ាលី** សមាជិកាគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញចូលរួមមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៦ (AIPA-46th) ដឹកនាំដោយ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា នៅប្រទេសម៉ាឡេស៊ី។

❖ **ឯកឧត្តមបណ្ឌិត ថែម វីឌ្យ៉ា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា៖

- បានទទួលជួបពិភាក្សាការងារជាមួយ **ឯកឧត្តម Antoine RIPOLL** អគ្គទីប្រឹក្សាផ្នែកទំនាក់ទំនងជាមួយសភាតំបន់អាស៊ី-អាគ្នេយ៍ និងជាតំណាងស្ថានទូតសហភាពអឺរ៉ុបប្រចាំតំបន់អាស៊ាន នៅបណ្ណាល័យឯកឧត្តមបណ្ឌិតប្រធានគណៈកម្មការទី៥។
- បានអញ្ជើញទទួលបដិសណ្ឋារកិច្ចស្វាគមន៍ ឯកឧត្តមប្រធានាធិបតីនៃសាធារណរដ្ឋហ្វីលីពីន និងលោកជំទាវ នៅអាកាសយានដ្ឋានអន្តរជាតិតេជោ និង
- បានអញ្ជើញដឹកនាំកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងសេចក្តីសម្រេចទាំង១៦ ដែលគណៈកម្មាធិការរៀបចំនឹងត្រូវលើកយកមកពិភាក្សាមហាសន្និបាតអាយប៉ាលើកទី៤៦ នៅប្រទេសម៉ាឡេស៊ី នៅសាលប្រជុំគណៈកម្មការទី៥ព្រឹទ្ធសភា។

❖ **ឯកឧត្តម ឆាយ វណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីទទួលទានតែសាមគ្គី High Tea ដែលរៀបចំដោយស្ថានទូតម៉ាឡេស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅស្ថានទូតម៉ាឡេស៊ី។

❖ **ឯកឧត្តម គង់ មុនីកា** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយ **ឯកឧត្តម TSUTSUMI Naohiro** ឯកអគ្គរដ្ឋទូតជប៉ុន ទទួលបន្ទុកកិច្ចការសិទ្ធិមនុស្ស សន្តិភាព និងស្ថិរភាពអន្តរជាតិ នៅស្ថានទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា។

❖ **ឯកឧត្តម សេង ម៉ារឌី** សមាជិកគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញចូលរួមជាភ្ញៀវកិត្តិយសក្នុងកម្មវិធីប្រគល់ពានរង្វាន់ដល់វីរជនស្វែងរកសន្តិភាពជូនកម្ពុជា **លោក Michael B Alfaro** និង**លោក Gary Franchi** នៅវត្តវិបស្សនារាម ហៅវត្តព្រះអង្គធំ នៅក្រុង Spartanburg រដ្ឋ South Carolina សហរដ្ឋអាមេរិក។

❖ **សមាជិក សមាជិកាព្រឹទ្ធសភា៖**

- បានអញ្ជើញចូលរួមសិក្ខាសាលាស្តីពី "កិច្ចសន្ទនាសភា៖ ការផ្សារភ្ជាប់ទំនាក់ទំនងសភារវាងសហភាពអឺរ៉ុប និងកម្ពុជា (Parliamentary Dialogue: EU-Cambodia Parliamentary Network)" នៅសាលសន្និសីទបន្ទាយស្រី វិមានរដ្ឋសភា និង
- បានអញ្ជើញចូលរួមពិធីរំលឹកខួបអនុស្សាវរីយ៍លើកទី៨០នៃបដិវត្តន៍ខែសីហា និងទិវាបុណ្យឯករាជ្យជាតិវៀតណាម នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា រាជធានីភ្នំពេញ។

- **សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖**

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា៖

- បានអញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី** ក្នុងពិធី៖
  - ទទួលសារតាំងពី ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព ទើបតែងតាំងថ្មី ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅវិមានព្រឹទ្ធសភា ចំនួន២លើក និង
  - ទទួលបដិសណ្ឋារកិច្ចស្វាគមន៍ ជំនួបសម្តែងការគួរសម ពិភាក្សាការងារ និងពិធីផ្សេងៗ ជាមួយភ្ញៀវអន្តរជាតិ នៅរាជធានីភ្នំពេញ ចំនួន៧លើក។
- បានអញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា អញ្ជើញដឹកនាំគណៈប្រតិភូកម្ពុជា ទៅបំពេញទស្សនកិច្ច និងចូលរួមពិធីរំលឹកខួបអនុស្សាវរីយ៍លើកទី៨០នៃបដិវត្តន៍ខែសីហា និងទិវាបុណ្យឯករាជ្យជាតិវៀតណាម នៅទីក្រុងហាណូយ សាធារណរដ្ឋសង្គមនិយមវៀតណាម ដោយក្នុងឱកាសនោះ **ឯកឧត្តមអគ្គលេខាធិការ** បានអញ្ជើញចូលរួមអម **សម្តេចតេជោប្រធានព្រឹទ្ធសភា** ក្នុងជំនួបពិភាក្សាការងារជាមួយឥស្សរជនជាន់ខ្ពស់វៀតណាម ចំនួន៣លើក និងក្នុងពិធីលៀងសាយភោជន៍ និង
- បានទទួលជួប **លោកជំទាវ ផ្លរីដា អែន ខាំមើល ភី ម៉ាយអូ** (Flerida Ann Camille P. Mayo) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋហ្វីលីពីន ប្រចាំព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាការងារ និងផ្លាស់ប្តូរយោបល់អំពីការបន្តពង្រឹងកិច្ចសហប្រតិបត្តិការនានា ដែលជាផលប្រយោជន៍រួមនៃស្ថាប័ន និងប្រទេសទាំងពីរ បន្ទាប់ពីជោគជ័យដ៏ត្រចះត្រចង់នៃទស្សនកិច្ចផ្លូវរដ្ឋរបស់ ឯកឧត្តមប្រធានាធិបតីនៃសាធារណរដ្ឋហ្វីលីពីន និងលោកជំទាវ នៅព្រះរាជាណាចក្រកម្ពុជា។

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា **ឯកឧត្តម ខេង សិទ្ធិគុណ** និង**ឯកឧត្តម អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញពិនិត្យទីកន្លែងត្រៀមរៀបចំទទួលដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់ ឯកឧត្តមប្រធានាធិបតីនៃសាធារណរដ្ឋហ្វីលីពីន និងលោកជំទាវ នៅព្រះរាជាណាចក្រកម្ពុជា។

❖ **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការស្តីទី **ឯកឧត្តម អោក បូរ៉ា** និង**ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានជូន និងទទួលដំណើររបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា អញ្ជើញដឹកនាំគណៈប្រតិភូកម្ពុជា ទៅបំពេញទស្សនកិច្ច នៅសាធារណរដ្ឋសង្គមនិយមវៀតណាម។

❖ **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមរៀបចំពិធីបដិសណ្ឋារកិច្ចស្វាគមន៍ ឯកឧត្តមប្រធានាធិបតីនៃសាធារណរដ្ឋហ្វីលីពីន និងលោកជំទាវ ក្នុងឱកាសទស្សនកិច្ចផ្លូវរដ្ឋ នៅព្រះរាជាណាចក្រកម្ពុជា និងបានចូលរួមពិធីលៀងសាយភោជន៍ផ្លូវរដ្ឋ រៀបចំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី** ជូនឯកឧត្តមប្រធានាធិបតីនៃសាធារណរដ្ឋហ្វីលីពីន និងលោកជំទាវ នៅវិមានសន្តិភាព និង

- ❖ **ឯកឧត្តម អោក ប៉ូរ៉ា** និងឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញទទួលដំណើរនិវត្តន៍របស់ **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា បន្ទាប់ពីការចូលរួម "សន្និសីទសាមគ្គីភាពសង្គមស៊ីវិលអន្តរជាតិលើកទី២ស្តីពី គំនិតផ្តួចផ្តើមអភិវឌ្ឍន៍សកល" នៅទីក្រុងហូហាត តំបន់ស្វយ័តម៉ុងហ្គោលី សាធារណរដ្ឋប្រជាមានិតចិន នៅអាកាសយានដ្ឋានអន្តរជាតិតេជោ។

- បានសហការ និងទាក់ទងជាមួយស្ថានទូតចិន ស្ថានទូតឥណ្ឌា មជ្ឈមណ្ឌលស្រាវជ្រាវច្បាប់ចិន-អាស៊ាន(CALRC) មជ្ឈមណ្ឌលឯកសារច្បាប់កម្ពុជា សមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន មូលនិធិចិនដើម្បីអភិវឌ្ឍន៍ជនបទ(CFRD) បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា (CADT) បណ្ណសារដ្ឋានជាតិ និងក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍ក្នុង-ក្រៅប្រទេសនានា ដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការអន្តរជាតិ ការស្នើសុំអាហារូបករណ៍ រៀបចំវគ្គបណ្តុះបណ្តាល ការស្វែងរកកៀរគរជំនួយ ព្រមទាំងការរៀបចំកម្មវិធីផ្សេងៗ។

## ៥-មុខងារអភិវឌ្ឍន៍ស្ថាប័ន

### ៥.១-សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភាបាន៖
  - អញ្ជើញដឹកនាំកិច្ចប្រជុំក្រុមការងារដោយមានការចូលរួមពី ឯកឧត្តមនាយកខុទ្ទកាល័យសម្តេចតេជោប្រធានព្រឹទ្ធសភា ឯកឧត្តមនាយកខុទ្ទកាល័យអនុប្រធានទី១ព្រឹទ្ធសភា ឯកឧត្តម លោកជំទាវជាថ្នាក់ដឹកនាំចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីពិនិត្យសម្រេចលើការប្រសិទ្ធនាមឈ្មោះបន្ទប់នៃអគារព្រឹទ្ធសភាថ្មីដែលកំពុងសាងសង់ និង
  - អញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកញ្ញា និងទិសដៅការងារខែតុលា ឆ្នាំ២០២៥ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។

- **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា និងក្រុមការងារបច្ចេកទេសសាងសង់អគារថ្មីនៃព្រឹទ្ធសភា បានអញ្ជើញអមដំណើរ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងជាប្រធានគណៈកម្មការសាងសង់អគារថ្មីនៃព្រឹទ្ធសភា អញ្ជើញចុះពិនិត្យវឌ្ឍនភាពនៃដំណើរការសាងសង់អគារថ្មីនៃព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា។

- **ឯកឧត្តម អោក ប៉ូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភាបាន៖
  - អញ្ជើញចូលរួមកិច្ចប្រជុំអន្តរស្ថាប័នស្តីពី ការកែទម្រង់របបសោធនសាធារណៈ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង
  - ដឹកនាំប្រជុំការងាររៀបចំប្រាក់បៀវត្សប្រចាំខែតុលា និងរៀបចំបោះផ្សាយអាណត្តិត្រីមាសទី៤ ឆ្នាំ២០២៥ ជាមួយនាយកដ្ឋានហិរញ្ញវត្ថុ នៅការិយាល័យឯកឧត្តមអគ្គលេខាធិការរង។

- **ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែកញ្ញា និងទិសដៅការងារខែតុលា ឆ្នាំ២០២៥ របស់អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី និងអគ្គនាយកដ្ឋានស្រាវជ្រាវ នៅសាលប្រជុំពិសេសក្រោម វិមានព្រឹទ្ធសភា។

### ៤.២-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ

- បានបោះផ្សាយអាណត្តិសម្រាប់ត្រីមាសទី៤ ជំពូក៦០ ៦១ ៦២ និង៦៤ បញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- បានស្នើសុំបុរេប្រទាន និងឥណទានបន្ថែម សម្រាប់ចំណាយលើបេសកកម្មក្រៅប្រទេសរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា។
- បានបង្វែរប្រាក់បៀវត្ស ប្រាក់បំណាច់ ប្រចាំខែកញ្ញា ឆ្នាំ២០២៥ និងប្រាក់ឧបត្ថម្ភសម្រាប់ពិធីបុណ្យភ្ជុំបិណ្ឌ ព្រមទាំងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិក សមាជិកាព្រឹទ្ធសភា សមាជិក សមាជិកាព្រឹទ្ធសភាចូលនិវត្តន៍ និងថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និវត្តជន មន្ត្រីនគរបាលសន្តិសុខ ជំនួយការផ្ទាល់ អ្នកបើកបររថយន្ត តាមរយៈប្រព័ន្ធធនាគារអេស៊ីលីដា។
- បានបង្វែរប្រាក់ប្រមុខរដ្ឋស្តីទី ប្រាក់សង្គមកិច្ចថ្នាក់ដឹកនាំព្រឹទ្ធសភា ប្រាក់ឧបត្ថម្ភពិនិត្យ និងព្យាបាលជំងឺមន្ត្រីរាជការ ប្រាក់៧%នៃប្រាក់បៀវត្សមន្ត្រីរាជការបង់ចូលបេឡាសោធននិវត្តន៍អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងប្រាក់ឧបត្ថម្ភមូលនិធិសង្គមកិច្ចមន្ត្រីរាជការ ប្រចាំខែកញ្ញា ឆ្នាំ២០២៥ តាមរយៈប្រព័ន្ធធនាគារអេស៊ីលីដា។
- បានបង្វែរប្រាក់វិភាគទានជូនអង្គភាពបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) របស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកញ្ញា ឆ្នាំ២០២៥។
- បានបង់ប្រាក់សំណែសចំណាយប្រចាំខែកញ្ញា ឆ្នាំ២០២៥ ទៅធនាគារអេស៊ីលីដា។
- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១០៥សំណើ ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗ ចំនួន៩៨សំណើ។
- បានដោះស្រាយសំណើផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ ចំនួន២០សំណើ។
- បានថតចម្លងឯកសារ ចំនួន១,០៨០ច្បាប់ ប្រើប្រាស់ក្រដាសអស់ ចំនួន៣៧,៦៤៧សន្លឹក។
- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្ម នៅតាមបណ្តាភូមិភាគទាំង៨ ចំនួន ៨៨លើក ស្មើនឹង៣៥៥នាក់។
- បានរៀបចំបោសសម្អាត តុបតែងលម្អសាល ព្រមទាំងផ្តល់សេវាបម្រើភេសជ្ជៈ ក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន២៩លើក។
- បានទទួលលិខិតចូល ចំនួន៧៥៣ច្បាប់ និងបញ្ជូនលិខិតចេញទៅក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ចំនួន៤០៩ច្បាប់។
- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៤០ច្បាប់ ស្មើនឹង១៦០នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិក សមាជិកាព្រឹទ្ធសភា ចំនួន៦ច្បាប់។

- បានចុះសួរសុខទុក្ខមន្ត្រីរាជការមានគ្រោះថ្នាក់ចរាចរណ៍ និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅរាជធានីភ្នំពេញ និងខេត្តកណ្តាល ចំនួន៩នាក់។
- ការងារកែលម្អសួនច្បារ និងបរិស្ថានក្នុងបរិវេណព្រឹទ្ធសភា រួមមាន៖
  - បានកាត់តម្រឹមស្មៅ មែកឈើ និងផ្កានានា ចំនួន១៧លើក។
  - បានបាញ់ថ្នាំសម្លាប់សត្វល្អិត និងស្មៅតាមសួនច្បារនានា ចំនួន២លើក និង
  - បានសម្អាតអនាម័យតាមអគារធ្វើការ និងក្នុងបរិវេណព្រឹទ្ធសភាជាប្រចាំ។
- បានបន្តសម្របសម្រួលការរៀបចំគូរប្លង់រចនាទេសភាពសួនច្បារស្រះត្រី និងសួនច្បារសាលពិសេសវិមានព្រឹទ្ធសភា។
- បានធ្វើបញ្ជីស្ថិតិមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកញ្ញា មានចំនួន៧១៩នាក់ (ស្រី២៩១នាក់) ក្នុងនោះ
  - មន្ត្រីរាជការស្ថិតក្នុងភាពទំនេរដោយគ្មានបៀវត្ស ចំនួន១៣នាក់។
  - មន្ត្រីរាជការស្ថិតនៅក្រៅក្របខ័ណ្ឌដើម ចំនួន៥នាក់។
  - មន្ត្រីរាជការមានមុខតំណែងគ្រប់គ្រង ចំនួន៤៩៥នាក់ និង
  - បុគ្គលិកជាប់កិច្ចសន្យា ចំនួន៩០នាក់ (ស្រី៣៦នាក់)។
- បានពិនិត្យសេចក្តីព្រាង និងសេចក្តីសម្រេចស្តីពី គោលការណ៍នៃការបើកផ្តល់ និងទទួលថវិការបស់អង្គភាពគ្រប់គ្រងបេឡាសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានប្រជុំគណៈកម្មការវាយតម្លៃបន្តកិច្ចសន្យា ដល់បុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលពិសេស២ វិមានព្រឹទ្ធសភា។
- បានធ្វើសេចក្តីសម្រេច ចំនួន១ច្បាប់ និងលិខិតបង្គាប់ការ ចំនួន១ច្បាប់។
- បានធ្វើតារាងបញ្ជាក់ប្រាក់បៀវត្ស ប្រាក់បំណាច់ផ្សេងៗ និងវិញ្ញាបនបត្របញ្ជាក់រយៈពេលបំពេញការងាររដ្ឋ ចំនួន៨ច្បាប់។
- បានធ្វើបញ្ជីរាយនាមមន្ត្រីរាជការស្នើសុំប្រាក់វិភាជន៍គ្រួសារ (ប្រពន្ធ-កូន) ប្រចាំខែកញ្ញា ឆ្នាំ២០២៥។
- បានទទួលអាហារូបករណ៍ និងបានបញ្ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន២នាក់ចូលរួមបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នៅសាធារណរដ្ឋប្រជាមានិតចិន។
- បានទទួលអាហារូបករណ៍ និងបានបញ្ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១៩នាក់ចូលរួមបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា សាកលវិទ្យាល័យវ៉ាន់ដា សាកលវិទ្យាល័យអាស៊ីអឺរ៉ុប សាកលវិទ្យាល័យជាតិគ្រប់គ្រង និងបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា។
- ការងារជួសជុលកែលម្អអគារ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ក្នុងបរិវេណវិមានព្រឹទ្ធសភា រួមមាន៖
  - បានបិតស្កុតការពារជ្រាបទឹកដំបូលអក្សរ VVV នៅសាលរង់ចាំខាងលិច-កើតអគារក្រហម។
  - បានប្តូរកញ្ចក់ទ្វារអាលុយមីញ៉ូម អូតូធំទ្វារអាលុយមីញ៉ូម ទទឹក ដំបូលស័ង្កសី សន្លឹកទ្វារ MC នៅសាលសិក្ខាសាលាខាងជើង សាលពិសេស៣ អគារG នាយកដ្ឋានរដ្ឋបាល និង

- បានជួសជុល ខាត់ លាប សំយ៉ាប ពិដាន នៅខាងមុខអគារស និងនាយកដ្ឋានរដ្ឋបាល។

- បានជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធអគារ បណ្ដាញទឹក បណ្ដាញអគ្គិសនី ត្រួតពិនិត្យជណ្ដើរយន្ត កំចាត់សត្វកណ្ដៀរ រៀបចំ និងផ្លាស់ប្ដូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារិម ប្រមូលសម្ភារខូច បិទលេខកូដសម្ភារសារពើភ័ណ្ឌ និងបំពាក់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀតក្នុងបរិវេណព្រឹទ្ធសភា ចំនួន៩៥គ្រឿង/លើក។
- បានធ្វើស្លាកលេខរថយន្តព្រឹទ្ធសភាថ្មី ជូនសមាជិកព្រឹទ្ធសភា ចំនួន១គ្រឿង។
- បានសម្របសម្រួលការងារការដ្ឋាន និងបានរៀបចំរបាយការណ៍វឌ្ឍនភាពការងារសាងសង់អគារថ្មីនៃព្រឹទ្ធសភា រៀងរាល់ ២សប្ដាហ៍ម្ដង គោរពជូនថ្នាក់ដឹកនាំព្រឹទ្ធសភា។
- បានបន្តស្រាវជ្រាវ និងរៀបចំសរសេរចងក្រងសៀវភៅអំពីប្រវត្តិ និងការប្រើប្រាស់អគារមួយចំនួននៅវិមានព្រឹទ្ធសភា។
- បានធ្វើរបាយការណ៍ស្ដីពី សកម្មភាព និងលទ្ធផលការងាររបស់សម័យប្រជុំលើកទី៣ និងលើកទី៤ នីតិកាលទី៥។
- បានធ្វើរបាយការណ៍ស្ដីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា ប្រចាំខែកញ្ញា ឆ្នាំ២០២៥ ទូលថ្វាយ **ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា។
- បានធ្វើរបាយការណ៍ស្ដីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកញ្ញា ឆ្នាំ២០២៥ ព្រមទាំងបានផ្សព្វផ្សាយលើគេហទំព័រព្រឹទ្ធសភា និងផ្ញើជូនក្រសួង ស្ថាប័នពាក់ព័ន្ធនានា និង
- បានធ្វើបទបង្ហាញ និងរបាយការណ៍ស្ដីពី ការប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកញ្ញា ឆ្នាំ២០២៥។

## ៤.៣-ការងារសេវាច្បាប់៖

- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ សេចក្ដីសម្រេច ប្រកាស និងលិខិតផ្សេងៗ ចំនួន៣០ច្បាប់ពីក្រសួង និងស្ថាប័ននានា។
- បានទទួលសេចក្ដីព្រាងច្បាប់ពីរដ្ឋសភាចំនួន៣ច្បាប់ និងសេចក្ដីព្រាងច្បាប់ពីទីស្ដីការគណៈរដ្ឋមន្ត្រីចំនួន១ច្បាប់ ព្រមទាំងបានថ្វាយ និងចែកគ្រប់សមាជិក សមាជិកាព្រឹទ្ធសភា។
- បានរៀបចំឯកសារជំនួយស្មារតីក្នុងកិច្ចដំណើរការនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ជូន៖
  - ថ្នាក់ដឹកនាំព្រឹទ្ធសភា ចំនួន៦លើក។
  - លេខាធិការសម័យប្រជុំព្រឹទ្ធសភា ចំនួន២លើក និង
  - ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៤លើក។
- បានធ្វើបច្ចុប្បន្នភាពកម្មវិធីចុះបេសកកម្មរបស់គណៈកម្មការទាំង១០ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំព្រឹទ្ធសភា លើកទី៣ និងលើកទី៤ នីតិកាលទី៥ ចំនួន៤លើក។
- បានធ្វើកំណត់ហេតុពិស្ដារ និងកំណត់ហេតុសង្ខេបនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ ចំនួន៦លើក។

- បានផ្តល់សេវារដ្ឋបាល បច្ចេកទេស ព័ត៌មាន ពិធីការ ទំនាក់ទំនងការងារ ធ្វើរបាយការណ៍ និងរៀបចំកំណត់បង្ហាញ ឯកសារផ្សេងៗ ជូនថ្នាក់ដឹកនាំព្រឹទ្ធសភា សមាជិក សមាជិកាគណៈកម្មការទាំង១០ និងក្រុមនានារបស់ព្រឹទ្ធសភា អញ្ជើញចុះបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ព្រមទាំងក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន៣៣៣លើក និង
- បានចុះបញ្ជី និងសម្រួលបញ្ជូនឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល ទទួលការតែងតាំងថ្មីទៅអង្គភាពប្រឆាំងអំពើពុករលួយ ចំនួន២នាក់។

### ៨.៤-ការងារស្រាវជ្រាវ៖

- បានរៀបចំឯកសារស្រាវជ្រាវ និងឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ ចំនួន៣ច្បាប់។
- បានសិក្សាស្រាវជ្រាវ៖
  - ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា។
  - របាយការណ៍របស់ធនាគារជាតិនៃកម្ពុជា និង
  - ការប្រមូលចំណូលពន្ធក្នុងស្រុកប្រចាំត្រីមាសទី២។
- បានសិក្សាស្រាវជ្រាវ និងតាមដាន៖
  - យុទ្ធសាស្ត្រស្តីពី ការគ្រប់គ្រងបំណុលសាធារណៈឆ្នាំ២០២៤-២០២៨។
  - របាយការណ៍ និន្នាការសេដ្ឋកិច្ច-សង្គម ប្រចាំខែរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
  - វឌ្ឍនភាពនៃការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយពាក់ព័ន្ធតាមវិស័យនានា។
  - យន្តការអនុវត្ត តាមដានត្រួតពិនិត្យ វាយតម្លៃ និងការគ្រប់គ្រងហានិភ័យ និង
  - ការអនុវត្តការធ្វើកំណែទម្រង់គោលនយោបាយចំណូល-ចំណាយ។
- បានតាមដានការរៀបចំសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦ និងការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤។
- បានតាមដាន និងចងក្រងឯកសារយុទ្ធសាស្ត្រជាតិស្តីពី ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា។
- បន្តចងក្រងទិន្នន័យលិខិតបទដ្ឋានគតិយុត្តតាមវិស័យរបស់គណៈកម្មការនានា។
- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច ប្រចាំសប្តាហ៍នៃខែកញ្ញា ឆ្នាំ២០២៥ ចំនួន៤ច្បាប់។
- បានបកប្រែ និងសង្ខេបព័ត៌មានសភាបញ្ចូលក្នុងសម្រង់សង្ខេបព័ត៌មានសំខាន់ៗប្រចាំថ្ងៃ ចំនួន២២៩ព័ត៌មាន និង
- បានបញ្ចូលព័ត៌មាន និងចាត់ថ្នាក់ទៅតាមវិស័យច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត (រាជកិច្ចពីលេខ៣៨-៤២ ឆ្នាំ២០២៤)។

### ៨.៥-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិកសមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា ចំនួន២៧លើក។
- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា

និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងបណ្តាញសង្គម ចំនួន៤,៤៦៤លើក។

- បានបញ្ចូល និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភា ចំនួន៤៦៣លើក។
- បានអញ្ជើញអ្នកសារព័ត៌មាន ចូលយកព័ត៌មានព្រឹទ្ធសភា និងពិធីផ្សេងៗ ចំនួន៦លើក។
- បានតាំងពិព័រណ៍រូបភាពសកម្មភាពរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភានៅខាងមុខព្រឹទ្ធសភា ចំនួន ១៣លើក។
- បានរៀបចំផលិតទស្សនាវដ្តីព្រឹទ្ធសភា ប្រចាំខែកញ្ញា ឆ្នាំ២០២៥។
- បានសិក្សាស្រាវជ្រាវ ចងក្រងព្រឹត្តិបត្រ និងផ្សព្វផ្សាយព័ត៌មានស្តីពី បច្ចេកវិទ្យាព័ត៌មាន ចំនួន ២៦ចំណងជើង។
- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធណេតវើក អ៊ីនធឺណែត ពង្រឹងពង្រីកការផ្គត់ផ្គង់ ថែទាំ និងជួសជុលឧបករណ៍ សម្ភារ បរិក្ខារបច្ចេកទេស ព្រមទាំងដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មាន ចំនួន១៩គ្រឿង/លើក។
- បានរៀបចំប្រព័ន្ធស្ទូឌីយ៉ូ ប្រព័ន្ធកាមេរ៉ា ប្រព័ន្ធប្រជុំនិម្មិត ព្រមទាំងបានរចនាផ្ទាំង Backdrop Background និងបញ្ចាំងផ្ទាំង LED ក្នុងកិច្ចប្រជុំ ជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយភ្ញៀវជាតិ-អន្តរជាតិ និងកម្មវិធីផ្សេងៗ ចំនួន៦៣លើក។
- បានទទួលឯកសារ ព្រឹត្តិបត្រ សៀវភៅច្បាប់ និងសៀវភៅជំនាញផ្សេងៗ ចំនួន៣៤ក្បាល ព្រមទាំងបានដាក់លេខកូដសៀវភៅ បោះត្រាបិទប័ណ្ណខ្ចី-សងសៀវភៅ ចំនួន៣០ក្បាល។
- បានផ្សព្វផ្សាយឯកសាររបស់ព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឯកសារច្បាប់ ឯកសារជំនាញផ្សេងៗ និងសៀវភៅជា E-Book តាមគេហទំព័រ www.elibrary.senate.gov.kh ចំនួន ៧,៦៧៣ក្បាល ដែលមានសាធារណជនចូលអាន ចំនួន១,០៣០នាក់ (ដោយគិតចាប់ពីខែមករា ឆ្នាំ២០២០ ដល់ខែកញ្ញា ឆ្នាំ២០២៥) និង
- បានទទួលឯកសារពីអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងបានរៀបចំចាត់ចែងតម្កល់រក្សាទុកឯកសារនៅបណ្ណសារដ្ឋាន ដោយបានរៀបចំសៀវភៅព្រឹត្តិបត្រព្រឹទ្ធសភា(ស្ទួន) ឆ្នាំ២០១៤ ចំនួន៥៤០ក្បាល ត្រួតពិនិត្យបញ្ចូលមាតិកាលិខិត និងមាតិកាសំណុំលិខិតទៅក្នុងប្រព័ន្ធកុំព្យូទ័រ ចំនួន៤១សំណុំ។

### ៤.៦-ការងារពិធីការ និងទំនាក់ទំនងអន្តរជាតិ៖

- បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ ជំនួបសម្តែងការគួរសម ពិភាក្សាការងារ និងពិធីផ្សេងៗ ចំនួន៤២លើក។
- បានរៀបចំសារលិខិតជូនពរ លិខិតអបអរសាទរ លិខិតថ្លែងអំណរគុណ និងលិខិតរំលែកទុក្ខរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា គោរពជូនឥស្សរជនជាន់ខ្ពស់ជាតិ-អន្តរជាតិ និងថ្នាក់ដឹកនាំតាមក្រសួង ស្ថាប័ននានា ចំនួន ៨លិខិត។

- បានរៀបចំលិខិតឆ្លើយតបជាភាសាអង់គ្លេស កំណាត់បង្ហាញ និងឯកសារផ្សេងៗ ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១៤ច្បាប់/លើក។
- បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិ ប្រចាំខែកញ្ញា ឆ្នាំ២០២៥ ចំនួន ១ច្បាប់។
- បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំនួន៩ច្បាប់។
- បានរៀបចំបែបបទស្នើសុំលិខិតឆ្លងដែនផ្លូវការជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងជំនួយការគណៈកម្មការព្រឹទ្ធសភា ចំនួន៣រូប និង
- បានរៀបចំឯកសារជំនួយស្មារតីស្តីពី ជម្លោះព្រំដែនគោករវាងកម្ពុជា-ថៃ។

### ៥.៧-ការងារអគ្គាធិការដ្ឋានៈ

- បានប្រជុំពិភាក្សាការងារអំពីលទ្ធផលការងារសង្គមកិច្ច និងការផ្តល់សេវាជាមួយអង្គភាពចំណុះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកញ្ញា ឆ្នាំ២០២៥ ចំនួន២២លើក។
- បានប្រមូល និងរៀបចំរបាយការណ៍ជាមួយនាយកដ្ឋានផែនការ និងសរុប នាយកដ្ឋានគ្រប់គ្រងបុគ្គលិក នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស និងបណ្ណសារដ្ឋានស្តីពី ការអនុវត្តផែនការការងារ និងគោលនយោបាយនានា របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានរៀបចំរបាយការណ៍ស្តីពី លទ្ធផលការងាររបស់នាយកដ្ឋានត្រួតពិនិត្យការងារសង្គមកិច្ច និងការផ្តល់សេវា ប្រចាំខែកញ្ញា ឆ្នាំ២០២៥។
- បានចុះត្រួតពិនិត្យវត្តមានជាក់ស្តែងតាមនាយកដ្ឋាននានា ប្រចាំខែកញ្ញា ឆ្នាំ២០២៥ ចំនួន២លើក ដើម្បីផ្ទៀងផ្ទាត់បញ្ជីវត្តមាន ដែលនាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ។
- បានបូកសរុប និងធ្វើរបាយការណ៍សម្រង់វត្តមាន ប្រចាំថ្ងៃ ចំនួន៣៨លើក ប្រចាំសប្តាហ៍ ចំនួន ៤លើក និងប្រចាំខែកញ្ញា ឆ្នាំ២០២៥ ដែលគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ។
- បានចុះត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពី បរិស្ថាន អនាម័យ ការខូចខាតសម្ភារតាមអគារ និងសណ្តាប់ធ្នាប់នៃការចតយានយន្តក្នុងបរិវេណព្រឹទ្ធសភា និង
- បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីរាជការតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## II-ទិសដៅការងារខែតុលា ឆ្នាំ២០២៥

### ១- មុខងារនីតិកម្ម

- ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំពេញអង្គព្រឹទ្ធសភា លើកទី៤ នីតិកាលទី៥។

### ២-មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយក្រសួង ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ និងចុះបេសកកម្ម ដើម្បីតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។

### ៣- មុខងារតំណាង

- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ពិភាក្សាការងារជាមួយអាជ្ញាធរដែនដី ពិនិត្យវឌ្ឍនភាពនៃការអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ ចូលរួមសិក្ខាសាលា វេទិកា កិច្ចប្រជុំនានា និងពិធីផ្លូវការផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា និង
- ត្រៀមទទួលដំណើរទស្សនកិច្ចរបស់សាធារណជន សិស្ស និងនិស្សិត ដើម្បីសិក្សាឈ្វេងយល់អំពីរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា។

### ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

- ត្រៀមផ្តល់សេវាចាំបាច់បម្រើការងារការទូតសភា ការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកា កម្មវិធីជំនួប កម្មវិធីផ្លូវការ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូនានា។
- ត្រៀមរៀបចំជូនគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា អញ្ជើញចូលរួមៈ
  - កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពី កិច្ចការសង្គម និងវប្បធម៌នៃសភាតំបន់អាស៊ី (APA) នៅទីក្រុងមូស្គូ សហព័ន្ធរុស្ស៊ី។
  - មហាសន្និបាតនៃសហភាពអន្តរសភាលើកទី១៥១ និងកិច្ចប្រជុំពាក់ព័ន្ធ (151st IPU) នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស នៅខែតុលា ឆ្នាំ២០២៥ និង
  - វេទិកាសន្តិភាពទីក្រុងប៉ារីសស្តីពី សម្ព័ន្ធភាពថ្មី ដើម្បីសន្តិភាព ប្រជាជន និងភពផែនដី នៅទីក្រុងប៉ារីស សាធារណរដ្ឋបារាំង។
- បន្តត្រៀមស្រាវជ្រាវ បកប្រែ និងរៀបចំឯកសារជំនួយស្មារតី សុន្ទរកថាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបជាមួយភ្ញៀវអន្តរជាតិក្នុងជំនួបសវនាការ កិច្ចប្រជុំ និងទស្សនកិច្ចនានា។

### ៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន

- បន្តអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានារួមមាន ការសាងសង់អគារថ្មី ការជួសជុល ថែទាំ កែលម្អបរិស្ថានអនាម័យ សួនច្បារ ប្រព័ន្ធអគ្គិសនី ប្រព័ន្ធទឹក ប្រព័ន្ធលូ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងប្រព័ន្ធសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា ប្រកបដោយសុខសុវត្ថិភាព។
- បន្តផ្តល់សេវាផ្គត់ផ្គង់សម្ភារ ថវិកា មធ្យោបាយដឹកជញ្ជូន ទំនាក់ទំនងជាមួយអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងសេវាសំខាន់ៗផ្សេងទៀតជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងាររបស់ខ្លួនឱ្យបានទាន់ពេលវេលា និងល្អប្រសើរ និង
- បន្តចុះសួរសុខទុក្ខមន្ត្រីរាជការលំហែមាតុភាព និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## III-សេចក្តីសន្និដ្ឋាន

ខែកញ្ញា ជាខែទី៣ នៃវិស្សមកាលរយៈពេលបីខែរបស់ព្រឹទ្ធសភា អគ្គលេខាធិការដ្ឋាន បានបង្កើនការផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកា គណៈកម្មការ ក្រុមយន្តការនានារបស់ព្រឹទ្ធសភា បំពេញមុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង របស់ខ្លួន ដើម្បីបិទបញ្ចប់ការងារស្របតាមផែនការសកម្មភាពការងាររយៈពេល៣ខែនៃវិស្សមកាល។

ស្ថិតក្នុងបរិបទនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានធ្វើរបាយការណ៍បូកសរុបសកម្មភាព និងលទ្ធផលការងាររយៈពេល៣ខែ របស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា គណៈកម្មការ ក្រុមយន្តការនានា ដើម្បីរាយការណ៍ក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភា។

ចំពោះការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានយកចិត្តទុកដាក់ខ្ពស់ក្នុងការផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងារការទូតសភាដោយសម្រេចបានលទ្ធផលល្អប្រសើរ។ ក្រៅពីបំពេញមុខងារស្នូលរបស់ខ្លួន ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបន្តសកម្មភាពការងាររួមចំណែកទ្រទ្រង់សមរភូមិមុខតាមរយៈការនាំយកអំណោយស្បៀងអាហារ សម្ភារប្រើប្រាស់ជូនកងទ័ព និងប្រជាពលរដ្ឋភៀសសឹក នៅតាមបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ។

ថ្ងៃព្រហស្បតិ៍ ១៣ រោច ខែ មិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ ធ្នូ ឆ្នាំ២០២៥

**អគ្គលេខាធិការ**

**ឡាយ សំកុល**